# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ២

បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# ការឱ្យដំណឹងអំពីសេចក្ដីសម្រេចតុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ

រៀបចំដោយៈ

-ឯកឧត្តម **គង់ តារាឆាត** ចៅក្រមតុលាការកំពូល

-ឯកឧត្តម **ហេង សុខណា** នាយកសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

"កិច្ចដំណើរការល្អនៃយុត្តិធម៌ព្រហ្មទណ្ឌ" គឺជាគោលបំណងដ៏សំខាន់មួយរបស់វិធាននៃនីតិវិធីព្រហ្មទណ្ឌដើម្បីធានានូវ "សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌" ដែលត្រូវបានទទួលស្គាល់ និងការពារសម្រាប់ពលរដ្ឋគ្រប់រូប ដោយសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ផ្អែកតាមមាត្រា ១០ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស, សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌ សំដៅដល់សិទ្ធិស្នើសុំឱ្យតុលាការដែលឯករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌នេះនៅក្នុងរឿងព្រហ្មទណ្ឌ គ្របដណ្តប់ទាំងលើ "សិទ្ធិ និងកាតព្វកិច្ច" នៅក្នុងរឿងរដ្ឋប្បវេណី និងលើ "ការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ"។ មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានបញ្ជាក់បន្ថែមពីវិសាលភាពនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកប ដោយសមធម៌នេះ ដោយផ្តោតទាំងចំពោះការសម្រេចលើការចោទប្រកាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ទាំងចំពោះការសម្រេចលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។

ការធានាការពារនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌នេះ ទាមទារឱ្យមានការគោរពនូវសិទ្ធិ ឬគោលការណ៍ជាមូលដ្ឋានសំខាន់មួយចំនួន ជាពិសេស សិទ្ធិពឹងពាក់តុលាការ[1], គោលការណ៍ឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់តុលាការ, គោលការណ៍នៃការជម្រះក្តីតាមច្បាប់[2], គោលការណ៍នៃការសន្មតជាមុនថាគ្មានទោស, សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[3], គោលការណ៍ចំពោះមុខ[4] និងសវនាការជាសាធារណៈ។ ចំពោះសិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវបានទទួលស្គាល់ និងការពារដោយរដ្ឋធម្មនុញ្ញ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ដោយឡែកផ្សេងទៀត។ ការធានាការគោរពសិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនៃ

1. មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ"។

2. កថាខណ្ឌទី១ នៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា "ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន"។

3. កថាខណ្ឌទី៨ នៃមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។

4. វាក្យខណ្ឌទី១ នៃមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់"។

នីតិវិធីតុលាការ តាមរយៈកិច្ចនីតិវិធីសំខាន់ៗមួយចំនួន ជាពិសេស ការកោះហៅ និងការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ។

ការកោះហៅ ជាកិច្ចនីតិវិធីតុលាការដែលត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនីតិវិធីក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីឱ្យបុគ្គលពាក់ព័ន្ធបានដឹងពីការចោទប្រកាន់ ឬការទាមទារនានាមកលើខ្លួន និងអាចប្រើប្រាស់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការដោយខ្លួនឯង និង/ឬដោយមានជំនួយពីមេធាវី។ បុគ្គលគ្រប់រូប ទាំងជនត្រូវចោទ ជនជាប់ចោទ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែទទួលបាននូវការកោះហៅឱ្យចូលរួមក្នុងកិច្ចនីតិវិធីតុលាការ ដើម្បីអាចចូលផ្តល់ចម្លើយ ធ្វើការបំភ្លឺ និងធ្វើការពិភាក្សាដេញដោលចំពោះការចោទប្រកាន់មកលើខ្លួន ឬចំពោះការទាមទាររបស់ខ្លួន និងចូលរួមក្នុងសវនាការជំនុំជម្រះក្តីស្របតាមគោលការណ៍ចំពោះមុខ។ គោលការណ៍ចំពោះមុខនេះ ធានានូវសិទ្ធិរបស់ភាគីទាំងសងខាងក្នុងការបានដឹងពីអំណះអំណាងទាំងអង្គហេតុ អង្គច្បាប់ និងភស្តុតាងដែលជាមូលដ្ឋាននៃការចោទប្រកាន់មកលើខ្លួន និងជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។ គោលការណ៍ចំពោះមុខនេះ ធានាថាគ្មានបុគ្គលណាម្នាក់នឹងត្រូវសម្រេចសេចក្តីដោយមិនត្រូវបានស្តាប់ចម្លើយ ឬមិនត្រូវបានកោះហៅនោះទេ។ ផ្អែកលើគោលការណ៍នេះ សេចក្តីសម្រេចរបស់តុលាការដែលធ្វើឡើងដោយមានវត្តមានរបស់ភាគីពាក់ព័ន្ធ នាពេលសវនាការ ត្រូវបានកំណត់ថាជាសាលក្រម ឬសាលដីកាចំពោះមុខ។ ប៉ុន្តែ លើការជាក់ស្តែង ទោះបីជាការកោះហៅត្រូវបានធ្វើឡើងត្រឹមត្រូវក៏ដោយ ប៉ុន្តែជារឿយៗមានករណីដែលជនជាប់ចោទ ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬដើមបណ្តឹងរដ្ឋប្បវេណី មិនបានចូលបង្ហាញខ្លួននៅពេលសវនាការតាមការកោះហៅនោះទេ ហើយករណីខ្លះទៀត ការកោះហៅមិនបានទៅដល់ភាគីម្ខាងដោយសារតែមូលហេតុផ្សេងៗ។ ទោះបីជា តាមគោលការណ៍ច្បាប់ការជំនុំជម្រះក្តីរបស់តុលាការត្រូវគោរពគោលការណ៍ចំពោះមុខក៏ដោយ តុលាការនៅតែអាចបន្តកិច្ចដំណើរការជំនុំជម្រះក្តីដល់អង្គសេចក្តីបានដដែល ក្នុងករណីដែលជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី បានដឹងអំពីការកោះហៅ ប៉ុន្តែ មិនបានចូលមកបង្ហាញខ្លួននៅពេលសវនាការទៅតាមកាលបរិច្ឆេទកំណត់។ ក្នុងករណីនេះ សាលក្រម ឬសាលដីការបស់តុលាការ ត្រូវបានកំណត់ថាជា

សាលក្រម ឬសាលដីកាដែលត្រូវចាត់ទុកថាចំពោះមុខ[5]។ សាលក្រមដែលចាត់ទុកថាចំពោះមុខ បើកសិទ្ធិឱ្យមានការប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ដូចគ្នានឹងករណីសាលក្រមកំបាំងមុខដែរ។ ទន្ទឹមនេះ តុលាការក៏នៅតែអាចបន្តនីតិវិធីជំនុំជម្រះក្តីបានដដែល ទោះបីជាជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ដោយគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីការកោះហៅនោះទេ។ ក្នុងករណីនេះ សាលក្រម ឬសាលដីការបស់តុលាការត្រូវបានកំណត់ថាជាសាលក្រម ឬសាលដីកាកំបាំងមុខ[6]។ សាលក្រមកំបាំងមុខ បើកសិទ្ធិឱ្យមានការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ចំពោះសាលក្រមកំបាំងមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខ ច្បាប់តម្រូវឱ្យធ្វើការជូនដំណឹងដល់ភាគីពាក់ព័ន្ធ។ ហេតុដូចនេះ ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ត្រូវតែទទួលបានការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌ។ ផ្អែកតាមកថាខណ្ឌទី១ នៃមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាឱ្យដំណឹងគឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់ត្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ។ ដើម្បីធានាថាការឱ្យដំណឹងពីសាលក្រមកំបាំងមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ធ្វើឡើងបានត្រឹមត្រូវ, ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីក្របខ័ណ្ឌគតិយុត្តនៃការឱ្យដំណឹងនេះ ដោយបញ្ជាក់ពីអ្នកដែលមានសមត្ថកិច្ចក្នុងការឱ្យដំណឹង *(១)* និងពីរបៀបនៃការឱ្យដំណឹងដែលត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ *(២)*។ ប៉ុន្តែ ផ្អែកលើការអនុវត្តជាក់ស្តែង មានសេចក្តីសម្រេចកំបាំងមុខ និងសេចក្តីសម្រេចដែលចាត់ទុកថាចំពោះមុខរបស់តុលាការជាច្រើន មិនអាចចូលជាស្ថាពរបាន ដោយសារតែភាគីដែលត្រូវទទួលដីកាឱ្យដំណឹងមិនមានលំនៅឋានច្បាស់លាស់នៅកម្ពុជា ឬនៅក្រៅប្រទេស ដែលករណីនេះទាមទារនូវដំណោះស្រាយមានលក្ខណៈច្បាស់លាស់ ដើម្បីអាចរាប់ពីចិរវេលានៃសិទ្ធិប្តឹងឧបាស្រ័យរបស់ភាគីពាក់ព័ន្ធ បាន និង

5. មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

6. មាត្រា ៣៦២ នៃក្រមនីវិធីព្រហ្មទណ្ឌ។

ទាមទារឱ្យមានការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់រយៈពេលវែង សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តស្របតាមការវិវត្តដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល *(៣)*។

## ១- សមត្ថកិច្ចក្នុងការឱ្យដំណឹងអំពីសេចក្ដីសម្រេចតុលាការ

ការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ គឺជានីតិវិធីមួយដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចាប់ពីមាត្រា ៤៨២ ដល់មាត្រា ៤៩០។ ផ្អែកតាមកថាខណ្ឌទី២ នៃមាត្រា ៤៨២, ដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវធ្វើតាមគំនិតផ្ដើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬរបស់ភាគី។ ដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការនេះ ត្រូវមានចុះនិទ្ទេស ដូចជា៖ ប្រភេទ និងការយោងនៃសេចក្ដីសម្រេចដែលត្រូវជូនដំណឹង, អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្ដីសម្រេច និងកាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង។ ទន្ទឹមនេះ ដីកានេះត្រូវបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបានប្រឆាំងនឹងសេចក្ដីសម្រេចដែលត្រូវបានជូនដំណឹង ដោយត្រូវភ្ជាប់ទៅជាមួយនឹងលិខិតចម្លងនៃសេចក្ដីសម្រេចដែលត្រូវជូនដំណឹង[7]។ ផ្អែកតាមច្បាប់ ផ្លូវតវ៉ាចំពោះសាលក្រមកំបាំងមុខ រួមមាន បណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍។ បណ្ដឹងទាស់ ត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ដោយផ្ដើមគិតចាប់ពី៖ (១)-ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមនេះត្រូវបានប្រគល់ឱ្យពិរុទ្ធជន ឬដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ (២)-ថ្ងៃដែលពិរុទ្ធជន ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីនេះ បានដឹងយ៉ាងពិតប្រាកដពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជន ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ បណ្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើក្នុងរយៈពេល ១ ខែ ដែលត្រូវផ្ដើមគិតចាប់ពី៖ (១)-ពេលប្រកាសសាលក្រម កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ និង (២)-ពេលទទួលបានដំណឹងពីសាលក្រម កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ ទោះបីជាការឱ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ។ ក្រៅពីនេះ បណ្ដឹងឧទ្ធរណ៍ក៏អាច

---

7. មាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ធ្វើបានផងដែរចំពោះសាលក្រមកំបាំងមុខ ប៉ុន្តែរយៈពេលប្តឹងឧទ្ធរណ៍នេះត្រូវផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់[8]។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា ការជូនដំណឹងពីដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា[9] និង អាជ្ញាសាលា[10] ឬដោយបុគ្គលផ្សេងទៀតតាមការស្នើសុំរបស់ព្រះរាជអាជ្ញា[11] ដែលរួមមាន ក្រឡាបញ្ជី, អាជ្ញាធររដ្ឋបាល, ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន, អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះក្រឡាបញ្ជី, អាជ្ញាធររដ្ឋបាល, អាជ្ញាធរពន្ធនាគារ, មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យជូនដំណឹងនេះ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា[12]។

## ២- របៀបនៃការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ផ្អែកតាមមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធដែលត្រូវទទួលការឱ្យដំណឹងនេះ **"បានដំណឹងអំពីសេចក្តីសម្រេចនោះ"**។ ទន្ទឹមនេះ, រយៈពេលបណ្តឹងទាស់របស់ពិរុទ្ធជន និងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវគិតចាប់ពីថ្ងៃដែលពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី "បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម" (មាត្រា ៣៦៨ និងមាត្រា ៣៧២) និង **"បានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា"** (មាត្រា ៤១២ និងមាត្រា ៤១៦)។ ក្នុងស្មារតីនេះ នៅក្នុងសាលដីកាលេខ ១៨០ ចុះថ្ងៃទី ០៣-០៧-២០១៧, តុលាការកំពូល បានសម្រេចថាសាលដីកាកំបាំងមុខលេខ ២៤ ក្រ.II.ស ចុះថ្ងៃទី ១៩-១១-២០១៤ របស់សាលាឧទ្ធរណ៍ មិនទាន់ចូលជាស្ថាពរនោះទេ ដោយតុលាការកំពូល សំអាងថា *"ផ្អែកតាមមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងមិនមែនធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ចនោះទេ"*។ តើការឱ្យដំណឹងពីសេចក្តីសម្រេចតុលាការត្រូវធ្វើឡើងតាមរបៀបណាខ្លះ ដើម្បីធានាថាភាគីពាក់ព័ន្ធបានដំណឹងយ៉ាងពិតប្រាកដអំពីសេចក្តី

8. កថាខណ្ឌទី៤ នៃមាត្រា ៤៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

9 . កថាខណ្ឌទី១ នៃមាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា"។

10 . កថាខណ្ឌទី១ នៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "ការជូនដំណឹងក៏អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ"។

11 . កថាខណ្ឌទី១ នៃមាត្រា ៤៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។

12 . កថាខណ្ឌទី២ នៃមាត្រា ៤៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។

សម្រេចនេះ? ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា ការជូនដំណឹងអំពីដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវធ្វើឡើងតាមរយៈការប្រគល់ *(ក)* ឬតាមគ្រប់មធ្យោបាយជាពិសេសក្នុងករណីដែលភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ *(ខ)* សំខាន់ឱ្យតែភាគីពាក់ព័ន្ធបានទទួលដំណឹងពីសាលាក្រម ឬសាលាដីកា ទោះបីជាការឱ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ។

## ក-ការឱ្យដំណឹងតាមវិធីប្រគល់

វិធីឱ្យដំណឹងដែលងាយស្រួលបំផុត និងដែលមិនមានវិវាទកម្ម គឺការឱ្យដំណឹងតាមវិធីប្រគល់។ ព្រះរាជអាជ្ញា ត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ។ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសលើសេចក្តីសម្រេចដើមពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ហើយភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនេះ។ ចំពោះការប្រគល់ដែលធ្វើឡើងដោយអាជ្ញាសាលា ឬដោយក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរ ពន្ធនាគារ មន្ត្រីនគរបាល ឬអាវុធហត្ថ ត្រូវធ្វើឡើងតាមរបៀបដូចខាងក្រោម៖

- **ករណីជួបប្រទះភាគីពាក់ព័ន្ធនៅលំនៅឋាន ឬទីកន្លែងដទៃទៀត៖** ក្នុងករណីជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬទីកន្លែងដទៃទៀត អ្នកប្រគល់ត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យដល់ភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ ហើយអ្នកប្រគល់ត្រូវចារលើសេចក្តីសម្រេចដើមថា លិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីដោយផ្ទាល់ដៃ និងត្រូវចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង ដោយឱ្យភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមនោះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់[13]។

- **ករណីអវត្តមាននៃភាគីពាក់ព័ន្ធ៖** ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ហើយអាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើមថា លិខិតចម្លងនៃសេចក្តីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន ព្រមទាំងចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួល

---

13 . មាត្រា៤៨៦ និងកថាខណ្ឌទី៣ នៃមាត្រា៤៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

លិខិត ត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម ហើយសេចក្តីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេច ត្រូវសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត[14]។ ច្បាប់តម្រូវឱ្យអ្នកដែលទទួល ត្រូវមានកាតព្វកិច្ចក្នុងការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យដល់ភាគីពាក់ព័ន្ធ។ ប៉ុន្តែ ច្បាប់មិនបានកំណត់ឱ្យបានច្បាស់អំពីផលវិបាកដែលកើតឡើង ក្នុងករណីដែលអ្នកទទួលមិនបានប្រគល់លិខិតចម្លងនេះដោយចេតនាក្តី ឬដោយការធ្វេសប្រហែសក្តី។ ប្រសិនបើអ្នកទទួលមិនបានប្រគល់បន្តឱ្យដល់ភាគីពាក់ព័ន្ធ ដោយសារតែការធ្វេសប្រហែសក្តី ឬដោយចេតនាក្តី តើការជូនដំណឹងនេះត្រូវចាត់ទុកជាការជូនដំណឹងដែលភាគីពាក់ព័ន្ធ "បានដឹងយ៉ាងពិតប្រាកដ" ស្របតាមស្មារតីនៃច្បាប់ដែរឬទេ?

- **ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់អាជ្ញាធរមូលដ្ឋាន៖** ក្នុងការអនុវត្តជាក់ស្តែង ពេលខ្លះភាគីពាក់ព័ន្ធបានដឹងអំពីការជូនដំណឹង ប៉ុន្តែមិនព្រមទទួលយកការជូនដំណឹងពីសេចក្តីសម្រេច ហើយពេលខ្លះអ្នកដែលមានវត្តមាននៅលំនៅឋានរបស់ភាគីពាក់ព័ន្ធមិនព្រមទទួលយកការជូនដំណឹងអំពីសេចក្តីសម្រេចនេះទេ។ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តនេះ, មាត្រា ៤៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានអនុញ្ញាតឱ្យអនុវត្តការជូនដំណឹងតាមរយៈការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចទៅមេឃុំ ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាម្នាក់ ក្នុងករណី ៣ យ៉ាងគឺ៖ (ទី១)-ករណីភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច, (ទី២)-ករណីគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ និង (ទី៣)-ករណីគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ព្រមទទួលសេចក្តីសម្រេចនោះទេ។ ចំពោះវិធីជូនដំណឹងនេះ, អ្នកប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាមួយ ត្រូវចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បន្ទាប់មក បុគ្គលដែលទទួលលិខិតចម្លងត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម ហើយសេចក្តីសម្រេចដើមនេះត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិត

---

14 . មាត្រា ៤៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់ឱ្យភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។ តើមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេចនេះ ត្រូវធ្វើបែបណាក្នុងករណីដែលភាគីពាក់ព័ន្ធ ឬបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធនៅតែមិនព្រមទទួលការប្រគល់លិខិតនៃសេចក្តីសម្រេចពីមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង?

## ខ-ការឱ្យដំណឹងក្នុងករណីភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់

ផ្អែកតាមមាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង"។ ចំពោះករណីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំទាន់បានកំណត់ឱ្យបានច្បាស់ពីនីតិវិធីលម្អិតសម្រាប់អនុវត្តសម្រាប់ករណីការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌដល់ភាគីពាក់ព័ន្ធដែលពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ ឬភាគីពាក់ព័ន្ធដែលរស់នៅក្រៅដែនដីជាតិនៅឡើយទេ។ ប៉ុន្តែ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យការជូនដំណឹងនេះអាចធ្វើឡើងតាមគ្រប់មធ្យោបាយ ធ្វើយ៉ាងណាឱ្យតែភាគីពាក់ព័ន្ធបានដឹងពីសេចក្តីសម្រេចរបស់តុលាការ។ តើមធ្យោបាយណាខ្លះដែលមានលក្ខណៈសមស្រប និងអាចមានភស្តុតាងបញ្ជាក់ថា ភាគីពាក់ព័ន្ធអាចទទួលបានដំណឹងយ៉ាងពិតប្រាកដពីដីកាឱ្យដំណឹងអំពីសេចក្តីរបស់តុលាការព្រហ្មទណ្ឌ ដើម្បីធានាឱ្យភាគីទទួលបាននូវសិទ្ធិប្តឹងទាស់ ឬប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់តាមកំណត់ច្បាប់។ ជាក់ស្តែង គ្រប់មធ្យោបាយនេះ អាចមានដូចជា ការជូនដំណឹងតាមប្រព័ន្ធទូរស័ព្ទ ឬប្រព័ន្ធទំនាក់ទំនងផ្សេងៗ ឬតាមការផ្សាយជាសាធារណៈ ឬតាមផ្លូវទូត ឬតាមរយៈសំណើសុំជំនួយទៅវិញទៅមកផ្អែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាដើម។

ក្នុងការអនុវត្តជាក់ស្តែង តើការឱ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការក្នុងករណីនេះត្រូវបានអនុវត្តដោយវិធីណា? កន្លងមក ចំពោះករណីដែលភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ការជូនដំណឹងពីសេចក្តីសម្រេចតុលាការ តែងត្រូវអនុវត្តតាមលំដាប់លំដោយហើយធ្វើឡើងតាមវិធីដែលបានកំណត់ក្នុងមាត្រា ៤៨៨។ នៅពេលដែលមានចំណារពីមេភូមិ

បញ្ជាក់ថាភាគីពាក់ព័ន្ធបានចេញពីមូលដ្ឋានបាត់មិនដឹងទៅរស់នៅទីណា លិខិតជូនដំណឹងនេះតែងត្រូវយកទៅបិទផ្សាយនៅសាលាឃុំ ឬសាលាសង្កាត់ដើម្បីជាការជូនដំណឹង។ បន្ទាប់មកសាលាជម្រះក្ដីពាក់ព័ន្ធ អាចនឹងធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលិខិតជូនដំណឹងនេះតាមបណ្ដាញសារព័ត៌មានក្នុងស្រុកតាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ។ ផ្អែកតាមទម្លាប់នៃការអនុវត្តការជូនដំណឹងតាមវិធីនេះរួចរាល់ក្រឡាបញ្ជីនឹងចារចូលជាស្ថាពរលើសេចក្ដីសម្រេចរបស់តុលាការ។ ប៉ុន្តែ នៅក្នុងសាលដីកាលេខ ១៨០ ចុះថ្ងៃទី ០៣-០៧-២០១៧, តុលាការកំពូល បានសម្រេចថា *ការជូនដំណឹងមិនមែនធ្វើឡើងគ្រាន់តែជាការបង្គ្រប់កិច្ចនោះទេ ប៉ុន្តែ ការជូនដំណឹងនេះត្រូវតែធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធបានទទួលដំណឹងពីសេចក្ដីសម្រេចនេះ ដោយតុលាការកំពូលយល់ថា ការជូនដំណឹងតាមរយៈការផ្សព្វផ្សាយជាសាធារណៈតែក្នុងសារព័ត៌មានក្នុងស្រុក ជាវិធីជូនដំណឹងដែលពុំអាចឱ្យជនជាប់ចោទដែលកំពុងរស់នៅក្រៅប្រទេស អាចទទួលបានដំណឹងពីសាលដីការបស់សាលាឧទ្ធរណ៍បានទេ នៅពេលដឹងច្បាស់ថាភាគីពាក់ព័ន្ធកំពុងរស់នៅក្រៅប្រទេស។*

ច្បាប់ជាធរមាន មិនបានកំណត់អំពីការជូនដំណឹងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្ដាញទំនាក់ទំនងសង្គម ដែលបច្ចុប្បន្នបានក្លាយជាមធ្យោបាយទំនាក់ទំនងដ៏មានប្រសិទ្ធភាព ហើយកំពុងមានការវិវឌ្ឍយ៉ាងឆាប់រហ័សនោះទេ។ ផ្អែកតាមស្មារតីនៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត បានសម្រេចគាំទ្រឱ្យការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការព្រហ្មទណ្ឌអាចធ្វើបានតាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្ដាញទំនាក់ទំនងសង្គម។ ប៉ុន្តែ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្ដាញទំនាក់ទំនងសង្គមសម្រាប់ធ្វើការជូនដំណឹងដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការនេះ គួរត្រូវអនុវត្តឡើងដោយមានការប្រុងប្រយ័ត្នខ្ពស់ ជាពិសេសលើភាពមិនអាចកំណត់បានច្បាស់ពីអត្តសញ្ញាណភាគីតាមប្រព័ន្ធទំនាក់ទំនងសង្គម (ករណីគណនីឈប់ប្រើប្រាស់ ឬគណនីក្លែងក្លាយ) ដែលមិនអាចបញ្ជាក់ពីភស្តុតាងថា ភាគីពាក់ព័ន្ធនឹងទទួលបានការជូនដំណឹងនេះយ៉ាងពិតប្រាកដនោះទេ។

## ៣- សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតវិស័យយុត្តិធម៌លើកទី១

ដោយការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនេះ ជាបញ្ហាប្រឈមជាក់ស្តែងក្នុងការអនុវត្តដែលធ្វើឱ្យសេចក្តីសម្រេចមួយចំនួនធំមិនអាចចូលជាស្ថាពរបាន ការឱ្យដំណឹងអំពីសេចក្តីសម្រេចតុលាការនេះ បានក្លាយជាប្រធានបទនៃកិច្ចពិភាក្សាក្នុងអង្គមហាសន្និបាតវិស័យយុត្តិធម៌លើកទី១។ តាមរយៈកិច្ចពិភាក្សានេះ អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាមួយចំនួន ដែលរួមមាន ៖ (ទី១)-បញ្ហាកង្វះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (ទី២)-ការអនុវត្តមិនបានត្រឹមត្រូវរបស់មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (ទី៣)-វិធីបញ្ជូនដែលបានកំណត់ក្នុងច្បាប់លែងឆ្លើយតបនឹងស្ថានភាពវិវឌ្ឍរបស់សង្គម និងបច្ចេកវិទ្យាឌីជីថល, (ទី៤)-ការអនុវត្តមិនត្រឹមត្រូវនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ និង (ទី៥)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព។

ដើម្បីដោះស្រាយបញ្ហាចំពោះមុខ និងក្នុងអំឡុងពេលនៃការរង់ចាំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, អង្គមហាសន្និបាតវិស័យយុត្តិធម៌លើកទី១ បានសម្រេចឯកភាពគ្នាលើវិធានការបំពេញបន្ថែម ដូចខាងក្រោម៖

១-ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្របតាមស្មារតីនៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-បន្ថែមលើការអនុវត្តនីតិវិធីនៃការជូនដំណឹងដែលបានអនុវត្តនាពេលកន្លងមក ស្របតាមមាត្រា ៤៨៨ និងមាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមរយៈសារព័ត៌មាន ឬតាមយន្តការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងវិស័យយុត្តិធម៌ ក្នុងករណីដែលភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន ឬពុំមានលំនៅឋានឬទីសំណាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌ និងតុលាការកំពូលនឹងដាក់ចេញនូវសេចក្តីណែនាំរួមអំពីការជូនដំណឹងនេះ ដើម្បីធានាបាននូវការឯកភាពក្នុងការអនុវត្ត។

៣-ក្នុងអំឡុងពេលរង់ចាំច្បាប់ស្តីពីអាជ្ញាសាលាត្រូវបានរៀបចំនិងអនុម័តឱ្យប្រើ, ក្រសួងយុត្តិធម៌ត្រូវរៀបចំឱ្យមានមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដែលនឹងទទួលបានប្រតិភូកម្ម

អំណាចពីអាជ្ញាសាលា ឬក្រឡាបញ្ជី ហើយដែលស្ថិតក្រោមការទទួលខុសត្រូវរួមរបស់ប្រធានសាលាជម្រះក្តី ដើម្បីអនុវត្តកិច្ចការបញ្ជូន។

៤-ក្រសួងយុត្តិធម៌ នឹងសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំឱ្យមានយន្តការរួមមួយ សំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចការបញ្ជូនឱ្យបានឆាប់រហ័ស និងឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ជាធរមាន។